- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតអគ្គសេនាធិការកងទ័ពជាតិកម្ពុជា
- ផ្អែកតាមសិក្ខាសាលា នៃការកសាងកងរាជអាវុធហត្ថឆ្នាំ ១៩៩៤ និង ដើម្បីបង្កើនការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សង្គម បង្ក្រាបរាល់អំពើល្មើសច្បាប់
- ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា ១** - ត្រូវបានបង្កើតសេនាធិការដ្ឋាន កងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម និង ក្រុងព្រះសីហនុ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់បញ្ជាការដ្ឋានកងអាវុធហត្ថ នៃ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២** - រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់សេនាធិការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម និង ក្រុងព្រះសីហនុ អាស្រ័យដោយអគ្គសេនាធិការកំណត់ ។

**មាត្រា ៣** - ប្រគល់ជូនអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាដាក់ស្ដែងក្នុង ការរៀបចំសេនាធិការដ្ឋាន កងរាជអាវុធហត្ថខាងលើ ។

**មាត្រា ៤** - អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៥** - អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ១០ អនក្រ

## ស្ដីពីការបង្កើតគណៈនិធានយោបាយឥណទានកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើ របស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ

## សម្រេច

**មាត្រា ១** - បង្កើតទិវាចលនាប្រជាពលរដ្ឋ-ចូលរួមធ្វើហត្ថកម្ម លើការងារធារាសាស្ត្រ ហៅថា "ទិវានយោបាយទឹកកសិកម្ម " ដែលត្រូវប្រារព្ធធ្វើនៅថ្ងៃទី ០៤ មិនាជារៀងរាល់ឆ្នាំ ។

**មាត្រា ២** - ទិសដៅនៃទិវានយោបាយទឹក កសិកម្ម គឺចលនាប្រជារាស្ត្រ កងយោធពលខេមរភូមិន្ទ នគរបាល អគ្គរាជការគ្រប់ផ្នែក គ្រប់ថ្នាក់ សិស្ស និស្សិត ដែលមានអាយុ ចាប់ពី ១៨ ឆ្នាំឡើងទៅក៏រិត មធ្យមសិក្សា និង ឧត្តម សិក្សាចូលរួមទាំងស្មារតី ទាំងសំភារៈ ក្នុងគោលបំណងដោះស្រាយទឹកដើម្បីបំរើវិស័យកសិកម្ម និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយបានប្រសើរឡើង ។

**មាត្រា ៣** - មន្ត្រី រាជការ ស៊ីវិល កងកំលាំងប្រដាប់អាវុធ និង ប្រជាពលរដ្ឋគ្រប់រូបមានភារកិច្ចចូលរួមធ្វើហត្ថកម្ម នេះចំនួន ១៥ ថ្ងៃ ក្នុងមួយឆ្នាំ ដោយគិតចាប់តាំងពីថ្ងៃទី ០៤ មិនា តទៅ ។ ដោយឡែក ចំពោះសិស្ស និស្សិត មានភារកិច្ចចូលរួមក្នុងរយៈពេល ៧ ថ្ងៃ ។

**មាត្រា ៤** - ក្រសួងមហាផ្ទៃ មានភារកិច្ចណែនាំ អភិបាលខេត្ត-ក្រុង ជ្រើសរើសទីកន្លែងជាក់ស្តែងសំរាប់ការដ្ឋាន និង ចលនាប្រជាពលរដ្ឋចូលរួមព្រមទាំងរៀបចំបំរុងផ្នែកសំភារៈ បំរើអោយចលនានេះទទួលបានប្រសិទ្ធិភាពនយោបាយ និង សេដ្ឋកិច្ចខ្ពស់ ។

**មាត្រា ៥** - ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ មានភារកិច្ចណែនាំ បច្ចេកទេស និង សហការជាមួយគណៈកម្មាធិការបុណ្យជាតិ និង បណ្តាខេត្ត-ក្រុង ក្នុងការអនុវត្តន៍ ។

**មាត្រា៦** - បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** - សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការបុណ្យជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន និង អភិបាលខេត្ត-ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

# អនុក្រឹត្យ លេខ ១១ អនក្រ

## ស្ដីពីការតែងតាំងអគ្គទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា

## ប្រចាំព្រះរាជាណាចក្រថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ស្ដេចក្រុមឃុន ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១** - តែងតាំងឯកឧត្តម សរ សម្បត្តិ ជាអគ្គទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ